# មេរៀនទី៤៣៖ បញ្ញត្តិទាំង ១០ប្រការ ( ខគ្គ១ )

## និក្ខមនំ ១៩៖១៦-២០៖១១

**មេរៀន** ( *យូធូបលីង* )៖ **https://youtu.be/mUS9nTDf_5s**

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** **https://youtu.be/_DNG3sx0P0I**

**គោលបំណង៖** ការស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះធ្វើឲ្យព្រះសប្បាយព្រះទ័យ

**ខគម្ពីរចងចាំ៖ ចោទិយកថា ៦៖៥** *“ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង”* ។

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំឲ្យបញ្ញត្តិមួយថ្មី https://youtu.be/lio2oGzBFz8

២. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ https://youtu.be/7WO74xMesGU

៣. គឺជាការល្អ https://youtu.be/Z91SULEHfho

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «តោះបង្កើតច្បាប់»



១. គ្រូចែកកុមារជាក្រុម ក្នុងមួយក្រុមមានកុមារពី ៣-៤នាក់

២.សុំឱ្យក្រុមនីមួយៗគិតអំពីច្បាប់សំខាន់បំផុតមួយសម្រាប់ថ្នាក់សាលាថ្ងៃអាទិត្យ។ (វាអាចជា ការស្តាប់ គ្រូ, យកព្រះគម្ពីរមកជាមួយ, ច្រៀងសរសើរដំកើងព្រះឲ្យលឺៗ, ពេលចង់និយាយត្រូវលើកដៃជាមុនសិន អធិស្ឋានឲ្យអស់ពីចិត្ត ឬការទុកចិត្តព្រះជាដើម។ល។)

៣. ឲ្យកុមារចែកចាយច្បាប់ទាំងនោះ ហើយឲ្យកុមារពន្យល់ថា ហេតុអ្វីបានជាច្បាប់ទាំងអស់នេះមានសារៈសំខាន់។ (មានច្បាប់គឺសំខាន់ណាស់ ពីព្រោះវាជួយឲ្យយើងចេះគោរពគ្នាទៅវិញទៅមកនិងមាន ឥរិយាបថល្អ នៅក្នុងថ្នាក់)។

### ៤. ការណែនាំមេរៀន

ថ្ងៃនេះ យើងនឹងនិយាយអំពីវិន័យ/បញ្ញត្តិមួយចំនួន ដែលព្រះបានបង្កើតរាប់ពាន់ឆ្នាំមកហើយ។ បញ្ញត្តិទាំងអស់នោះត្រូវបានហៅថាបញ្ញត្តិទាំង១០ប្រការ។ ព្រះបានប្រទានបទបញ្ញត្តិដល់យើង ពីព្រោះព្រះអង្គចង់ជួយយើងឲ្យដឹងពីរបៀបរស់នៅ ដូច្នេះហើយយើងអាចធ្វើឲ្យព្រះសប្បាយព្រះទ័យបាន ។ នៅពេលដែលយើងស្តាប់បង្គាប់ ហើយធ្វើតាមបញ្ញត្តិរបស់ទ្រង់ បានបង្ហាញថាព្រះពិតជាមានសារៈសំខាន់ណាស់សំរាប់យើង។ ធ្វើដូច្នេះគឺធ្វើឲ្យព្រះសប្បាយព្រះទ័យ! មនុស្សមួយចំនួន គិតថាការធ្វើតាមបញ្ញត្តិរបស់ព្រះមានន័យថា យើងនឹងមិនអាចមានជីវិតសប្បាយរីករាយបានឡើយ ប៉ុន្តែវាគឺមិនដូច្នោះនោះទេ។ ព្រះបានប្រទានបញ្ញត្តិឲ្យយើង ពីព្រោះព្រះអង្គស្រលាញ់យើង។ បញ្ញត្តិរបស់ទ្រង់ជួយ និងការពារយើង ឲ្យចេះធ្វើការសំរេចចិត្តឲ្យបានប្រសើរនៅក្នុងជីវិតរស់នៅ។ សូមស្វែងយល់ជាមួយគ្នាអំពីបញ្ញត្តិដែលព្រះបាន ប្រទានមកដល់យើង ពីព្រោះបញ្ញត្តិរបស់ទ្រង់ប្រៀបដូចជាកញ្ចក់ឆ្លុះសំរាប់យើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ បានប្រាប់យើងអំពីបុរសម្នាក់ឈ្មោះថាម៉ូសេ។ ម៉ូសេបានឡើងទៅលើភ្នំស៊ីណាយដើម្បីថ្វាយបង្គំព្រះ។ សូមឲ្យយើងសាកសំដែងកាយវិកាជាការដើរឡើងទៅលើភ្នំ (*សូមឲ្យកុមារដើរនៅនឹងមួយកន្លែង*) ចូរយើងលុតជង្គង់របស់យើងដើម្បីថ្វាយបង្គំព្រះ (*សូមឲ្យកុមារលុតជង្គង់ចុះ*)។ នៅពេលម៉ូសេបានឡើង ដល់កំពូលភ្នំស៊ីណាយ ព្រះជាម្ចាស់បានគង់នៅទីនោះ។ ព្រះបានមានបន្ទូលជាមួយម៉ូសេ! ដោយទ្រង់បានប្រាប់ ម៉ូសេពីរឿងសំខាន់ ១០យ៉ាង។ យើងហៅរឿងសំខាន់នោះថា បញ្ញត្តិទាំង១០ប្រការ។ តើប្អូនអាចនិយាយ ឃ្លានេះបានទេ? (សូមអោយកុមារនិយាយថា *"បញ្ញត្តិទាំង១០ប្រការ"* )។ បញ្ញត្តិ១ នៅក្នុងចំណោមបញ្ញត្តិទាំង១០ប្រាប់យើងពីការគោរពកោតខ្លាចព្រះ។ ព្រះបានសរសេរបញ្ញត្តិទាំងអស់ នោះនៅលើផ្ទាំងថ្មធំៗ ដើម្បីឲ្យម៉ូសេនិងជនជាតិអ៊ីស្រាអែលនឹង ចងចាំថាក្រឹត្យវិន័យទាំងនោះមានអ្វីខ្លះ។

**បញ្ញត្តិទី១៖ និក្ខមនំ ២០៖៣** កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ។ បញ្ញត្តិទី១ប្រាប់ យើងថាព្រះគឺសំខាន់ជាងមនុស្សគ្រប់គ្នាទាំងអស់ ព្រះជាទី១។

**បញ្ញត្តិទី២៖ និក្ខមនំ ២០៖៤** កុំឲ្យឆ្លាក់ធ្វើរូបណាសំរាប់ឯងឲ្យសោះ។ បញ្ញត្តិទី២ ប្រាប់យើងថាកុំឲ្យធ្វើរូបណាដើម្បីថ្វាយបង្គំឲ្យសោះ។ មនុស្សនៅសម័យនោះពេលខ្លះឆ្លាក់ថ្ម ឬឆ្លាក់ឈើធ្វើដូចជារូបមនុស្សហើយពួកគេចាត់ទុករូបនោះដូចជាព្រះ។ តើនោះវាមិនមែនជារឿងឆោតល្ងង់ទេឬអី? ព្រះចង់ឲ្យពួកគេចាំថា ទ្រង់គឺជាព្រះពិតតែមួយគត់។

**បញ្ញត្តិទី៣៖ និក្ខមនំ ២០៖៧** កុំឲ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា ជាព្រះនៃឯងជាអសារឥតការឡើយ។ បញ្ញត្តិទី៣ ព្រះបានប្រទានឲ្យម៉ូសេ គឺមនុស្សទាំងអស់គួរតែប្រុងប្រយត្ន័ពីរបៀបដែលពួកគេ ប្រើព្រះនាមរបស់ទ្រង់។ ព្រះសំខាន់ណាស់ ហើយវាជារឿងមិនត្រឹមត្រូវនោះទេ ដែលយកព្រះនាមរបស់ព្រះមកលេងសើច ឬប្រើព្រះនាមទ្រង់នៅក្នុងកំហឹងរបស់យើង។

**បញ្ញត្តិទី៤៖ និក្ខមនំ ២០៖៨** ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ។ បញ្ញត្តិទី៤ គឺ ក្នុង១សប្តាហ៍សូមរក្សា១ថ្ងៃគឺជា ថ្ងៃពិសេសដើម្បីថ្វាយបង្គំព្រះ ជាថ្ងៃសំរាប់មកព្រះវិហារ។

ហេតុផលមួយដែលព្រះបានប្រទានបញ្ញត្តិទាំងអស់នោះ ដល់យើងគឺការរក្សាយើងឲ្យមាន សុវត្ថិភាព ហើយព្រះបង្ហាញឲ្យឃើញថាទ្រង់ស្រលាញ់យើងប៉ុនណា។ វាគឺជាជម្រើសរបស់យើងដែលជ្រើសរើសយកការដើរតាមបញ្ញត្តិរបស់ទ្រង់ ឬក៏អត់។ នៅពេលដែលយើងដើរតាមបញ្ញត្តិរបស់ព្រះ យើងនឹងនិយាយថា យើងយល់ស្របថាព្រះជ្រាបពីការដែលល្អឥតខ្ចោះ ហើយយើងនឹងធ្វើឲ្យព្រះ សប្បាយព្រះទ័យ។ ចូរយើងទូលថ្វាយទៅព្រះ ថាយើងចង់ធ្វើឲ្យព្រះអង្គសប្បាយព្រះទ័យ ដោយសារយើងទុកចិត្តទ្រង់ ហើយធ្វើតាមបញ្ញត្តិរបស់ទ្រង់។

## ៦. សំនួរពិភាក្សា

១. តើអ្នកណាឡើងទៅលើកំពូលភ្នំដើម្បីទទួលបញ្ញត្តិពីព្រះ? *(ម៉ូសេ)*

២. តើភ្នំនោះឈ្មោះអ្វី? *(ភ្នំស៊ីណាយ)*

៣. តើហេតុអ្វីបានជាព្រះប្រទានបញ្ញត្តិឲ្យយើង? *(ព្រះចង់ការពារយើង)*

៤. តើព្រះមានព្រះទ័យបែបណានៅពេលដែលយើងធ្វើតាមបញ្ញត្តិរបស់ព្រះអង្គ?
*(ព្រះអង្គសប្បាយព្រះទ័យ)*

៥. យើងបានរៀនពីបញ្ញត្តិ ៤ រួចមកហើយ តើប្អូនអាចធ្វើអ្វីបាន ដើម្បីគោរពតាមបញ្ញត្តិ ទាំង៤នេះ?

*(សូមចងចាំថាព្រះគឺជាទី១ កុំថ្វាយបង្គំរូបព្រះ ប្រើព្រះនាមព្រះដោយការគោរព ទៅព្រះវិហាររៀងរាល់ថ្ងៃអាទិត្យ)*

**៧. ល្បែងកំសាន្ត « ដំណើរចងចាំពីបញ្ញត្តិទាំង១០ប្រការ »**

សម្ភារៈដែលត្រូវការ ៖ ក្រដាសដែលមានសរសេរបញ្ញត្តិទាំង ៤ ប្រការ និងកៅអីចំនួន ៤



១. សូមបិទក្រដាសបញ្ញាត្តិទាំង ៤ ប្រការនៅលើកៅអីទាំង៤

២. ដាក់កៅអីទាំង៤ នៅជ្រុងទាំង៤នៃបន្ទប់រៀន សូមទុកចន្លោះធំល្មមសម្រាប់ឲ្យកុមាររាំនៅចំកណ្ដាល

៣. សូមចាក់ភ្លេងឲ្យកុមាររាំ



៤.នៅពេលភ្លេងឈប់កុមារអាចត្រូវរត់ទៅកាន់កៅអីមួយណាក៏បាន ហើយឈរនៅជុំវិញនោះ។

៥. គ្រូអាចជ្រើសរើសកុមារដែលឈរនៅជុំវិញកៅអីមួយណាក៏បាន ហើយឲ្យពួកគេអានបញ្ញាត្តិ ដែលបិទជាប់ជាមួយកៅអីនោះ។

៦. សូមចាក់ភ្លេងម្តងទៀត ហើយឲ្យកុមាររាំនិង ជ្រើសរើស កៅអីម្តងទៀត។ គ្រូសូមជ្រើសរើសកៅអីផ្សេង ហើយឲ្យ កុមារអាននូវខគម្ពីរដែលបិទជាប់នឹងកៅអីនោះ។

៧. បន្តលេងល្បែងនេះរហូតដល់បញ្ញាត្តិទាំង ៤ ប្រការនោះបានអានអស់។

**៨. ខគម្ពីរចងចាំ**

**ចោទិយកថា ៦៖៥** *“ ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង ”។*

**៩. ហត្ថកម្ម**

១. បោះពុម្ពរូបភាពបន្ទះថ្ម (ដែលមាននៅទំព័រខាងក្រោម)

២. សូមឲ្យកុមារសរសេរបញ្ញត្តិទាំង៤ប្រការ នៅលើបន្ទះថ្មនោះ (ឬប្រសិនបើកុមារមិនអាចសរសេរបានទេ សូមថតចម្លងបញ្ញត្តិទាំងនោះចេញមក ឲ្យកុមារកាត់ហើយបិទនៅលើបន្ទះថ្មនោះ)។

**១០. ចំរៀង** (រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ការធ្វើតាមព្រះយេស៊ូវគឺមិនមែនជាការស្ដាប់តាមក្រឹត្យវិន័យទេ គឺការដែលស្គាល់ពីព្រះអង្គ។ ទោះជា-យ៉ាងណាក៏ដោយការស្ដាប់បង្គាប់របស់យើង ក្នុងការគោរព និងថ្វាយសិរីរុងរឿងដល់ព្រះនៅក្នុងជីវិតប្រចាំថ្ងៃ អនុញ្ញាតឲ្យទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវបានរីកចម្រើនឡើង។ នៅពេលដែលយើងគោរព និងធ្វើតាមព្រះ ព្រះពររបស់ទ្រង់នឹងបង្ហូរមកកាន់យើង ហើយហូរទៅកាន់អ្នកដទៃទៀតដែលនៅ ជុំវិញយើង។ តើអ្នកបានទទួលព្រះពរអ្វីខ្លះពីការបង្រៀនក្មេងៗទាំងអស់នេះ? អធិស្ឋានសូមឲ្យពន្ធ័កិច្ច ដែលអ្នកចូលរួមក្នុងថ្ងៃនេះ ជួយសិស្សរបស់អ្នក ឲ្យមានបទពិសោធន៍ជាមួយនឹង ព្រះពររបស់ព្រះ។ សូមឲ្យអ្នកបានឃើញពីផលផ្លែនៃពន្ធ័កិច្ចរបស់ព្រះតាមរយៈការស្ដាប់បង្គាប់របស់អ្នក។

១. កុំឲ្យមានព្រះឯណាទៀត នៅចំពោះអញឲ្យសោះ

២. កុំថ្វាយបង្គំរូបព្រះឲ្យសោះ

៣. សូមប្រុងប្រយត្ន័ក្នុងការ ប្រើព្រះនាមព្រះ

៤. សូមរក្សាថ្ងៃបរិសុទ្ធរបស់ ព្រះជាថ្ងៃពិសេស

